**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

## ផ្ញើជូន

## លោកជំទាវ អោម គីមលី ព្រមទាំងក្រុមគ្រួសារ

**លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ជាទីស្រលាញ់រាប់អានដ៏ជ្រាលជ្រៅ !**

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ី មេបញ្ជាការរង កងទ័ពជើងគោក** បានទទួលមរណភាពនៅថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង១១:១០ នាទីព្រឹក ក្នុងជន្មាយុ៦៧ឆ្នាំ ដោយរបួសចាស់សើរើ។

មរណភាពរបស់**ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ី** មិនត្រឹមតែជាការបាត់បង់នូវស្វាមី ឪពុក ឪពុកក្មេក ជីតាជាទីគោរពស្រលាញ់ដ៏ជ្រាលជ្រៅ និងប្រកបដោយព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់ចំពោះក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់នាយទាហានឆ្នើមមួយរូប ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងប្រកបដោយឆន្ទៈមនសិការដ៏មោះមុតក្នុងបុព្វហេតុបម្រើ **ជាតិ សាសនា ព្រះមហាក្សត្រ** និងបានការពារបូរណភាពទឹកដីជាវៀងរហូតមក។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយ **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ។ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជះបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់**ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ី** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ អោម គីមលី ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ និងភរិយា។

ថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**